# របាយការណ៍ប្រចាំខែតុលា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែតុលា ឆ្នាំ ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **<u>ស្ថានភាពមន្ត្រីរាជការ</u>**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣១ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **<u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>**÷

- ចូលរួមវេទិកាសាធារណៈ ចំនួន ០១ លើក
- ចូលរួមសិក្ខាសាលា ស្តីពីគម្រោងលើកកម្ពស់សន្តិសុខស្បៀង តាមសហគមន៍ជនបទ និងទីប្រជុំជនរណប ថ្ងៃទី១៧ កញ្ញា ឆ្នាំ២០១៥ នៅសាលប្រជុំផអ៣
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី១៦អណត្តិទី២ ឆ្នាំទី២ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី ២២ កញ្ញា ឆ្នាំ២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីចែករង្វាន់ដល់សិស្សទទួលជ័យលាភី និទ្ទេស A B C ថ្ងៃទី១៨ កញ្ញា ២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រជុំផ្សព្វផ្សាយពីលទ្ធផលទិន្នផលក្នុងស្រុកសរុបបឋម GDP ថ្ងៃទី២១ កញ្ញា ២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សាក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ពីការអនុវត្ត CEDAW អនុសាសន៍សម្តេចតេជោ ច្បាប់ពាក់ព័ន្ធនឹងការលើកកម្ពស់ស្ត្រី ថ្ងៃទី២៩ កញ្ញា ២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំអង្គការសង្គមស៊ីវិលស្តីពីទំនាស់ដីធ្លី ធនធានធម្មជាតិ និងកិច្ចសុំអន្តរាគមន៍ពីអាជ្ញាធរ ថ្ងៃទី ២៣ កញ្ញា ២០១៥ សាលប្រជុំសាលាខេត្ត
- ចូលរួមវេនកាន់បិណ្ឌនៅវត្តប៉ាធា ថ្ងៃទី២៧ កញ្ញា ២០១៥
- ចូលរួមបើកការដ្ឋានសាងសង់សកលវិទ្យាល័យខេត្តក្រចេះ ថ្ងៃទី២៦ កញ្ញា ២០១៥ នៅសង្កាត់អូរឬស្សី ក្រុងក្រចេះ
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធិផលនានា នៅវត្តភ្នំសុពណ៌កាឡើ ថ្ងៃទី២៥ កញ្ញា ២០១៥
- ចូលរួមកាន់បិណ្ឌនៅវត្តក្រគរថ្ងៃទី ០២ តុលា ២០១៥
- ចូលរួមពិធីសំណេះសំណាល សួរសុខទុក្ខ លោកគ្រូ អ្នកគ្រូ ថ្ងៃទី០២ តុលា ២០១៥ នៅវិទ្យាល័យព្រះកុសុមៈ
- ចូលរួមជាអធិបតីក្នុងពិធីមិទ្ទិញ ទិវាមនុស្សចាស់ ថ្ងៃ០១ តុលា ២០១៥ នៅសាលមហោស្រព

- ចូលរួមពិធីប្រកាសមុខតំណែងថ្មីរបស់មន្ទីរបរិស្ថាន ថ្ងៃទី០៦ តុលា ២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំផ្សព្វផ្សាយពីដំណើរការរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សថ្ងៃទី ៦ ខែតុលា ឆ្នាំ២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីប្រកាសសមាសភាពថ្នាក់ដឹកនាំសមាគមអតីតយុទ្ធជនកម្ពុជា ថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមទិវាទេសចរពិភពលោក ថ្ងៃទី ៨ តុលា ២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រជុំប្រកាសការវាស់វែង និងចុះបញ្ជីដីរដ្ឋ ថ្ងៃទី០៨ តុលា ២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមគោរពវិញ្ញាណក្ខន្ធព្រះករុណា ព្រះមហាវីរៈក្សត្រ ថ្ងៃទី ១៦ តុលា ២០១៥ នៅសាលមហោស្រពខេត្តក្រចេះ
- ចូលរួមប្រជុំពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្ងៃទី២០ តុលា ២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ
- ចូលរួមដេញថ្លៃផ្លូវជនបទ ថ្ងៃទី១៩ តុលា ២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើគម្រោងកម្មវិធីវិនិយោគទាំងបីប្រភេទថ្ងៃទី ២២ តុលា ២០១៥ នៅសាលប្រជុំនៃមន្ទីរផែនការ
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យប្រចាំត្រីមាសទី៣ ថ្ងៃទី ២៣ តុលា ២០១៥ នៅសាលប្រជុំសាលាខេត្ត ។

3. **<u>សកម្មភាពតាមការិយាល័យ</u>**÷

3.1. **<u>ការិយាល័យរដ្ឋបាល និងបុគ្គលិក</u>**÷

ក. <u>ផ្នែកការងារលិខិតចូល</u> ÷ សរុបចំនួន ៥៣ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០១លេខ
- លិខិតរបស់ក្រសួងសាម៉ី ចំនួន ០៨លេខ
- លិខិតក្រសួងនានា ចំនួន ៥លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៣៩លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ៤២ លេខ ក្នុងនោះមានៈ

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ១៩លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ២៣លេខ

គ. <u>លិខិតឧទ្ទេសនាម</u>÷ សរុបចំនួន០៩លេខ

ឃ. <u>ផ្នែកការងារលិខិតបញ្ជាបេសកកម្ម</u>÷ សរុបចំនួន ០៧ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកម្មលោកប្រធានមន្ទីរ ពីឯកឧត្តមអភិបាលខេត្ត ចំនួន ០១ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ០៦ លេខ

ង. ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **ការិយាល័យផ្លូវជនបទ÷**

**សកម្មភាពការងារ÷**

- ក្រុមការងារផ្លូវជនបទចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងទិន្នន័យ និងមូលដ្ឋានប្រព័ន្ធព័ត៌មានភូមិសាស្រ្ត (GIS) នៅមន្ទីរអភិវឌ្ឍន៍ខេត្តមណ្ឌលគិរី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គភាពលទ្ធកម្មសាលាខេត្តក្រចេះ និងក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចុះពិនិត្យ និងវាយតម្លៃប្រគល់ ទទួលផ្លូវភូមិខ្សាត់ ទៅភូមិស្ទឹងទ្រ ប្រវែង ៦ ៨០០ ម៉ែត្រ និងលូចំនួន ០៩ កន្លែង ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ
- ក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចុះពិនិត្យ និងសិក្សាផ្លូវ ភូមិឥន្ទជ័យ ប្រវែង ១១ ៥០០ ម៉ែត្រ ស្ថិតឃុំបឹងចារ ស្រុកសំបូរ
- ក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចុះពិនិត្យ និងសិក្សាផ្លូវ ភូមិខ្សាច់ ប្រវែង ១៦ ០០០ ម៉ែត្រ ស្ថិតឃុំកញ្ជរ ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល
- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈប្រចាំ ផ្លូវស្រែទ្រៀក-វាលកន្សែង ប្រវែង ៦ ៣០០ ម៉ែត្រ ស្ថិតនៅឃុំជីរោទ៍ ស្រុកឆ្លូង និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង។

**លទ្ធផលការងារ÷**

- ការងារជួសជុលផ្លូវភូមិខ្សាត់ទៅភូមិស្ទឹងទ្រ ប្រវែង ៦ ៨០០ ម៉ែត្រ ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ លទ្ធផលសម្រេចបាន ១០០%
- ការងារជួសជុលថែទាំជាលក្ខណៈប្រចាំផ្លូវស្រែទ្រៀក-វាលកន្សែងប្រវែង ៦ ៣០០ ម៉ែត្រ ស្ថិតនៅឃុំជីរោទ៍ ស្រុកឆ្លូង និងផ្លូវរលៀក-ប្រម៉ា ប្រវែង ១០ ៨០០ ម៉ែត្រ ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង លទ្ធផលសម្រេចបាន ៩០%។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷**

- សាងសង់អណ្តូងស្នប់ថ្មីបានចំនួន ០៨ អណ្តូង
  - ស្រុកចិត្របុរី ០៦ អណ្តូង
  - ស្រុកឆ្លូង ០១ អណ្តូង
  - ក្រុងក្រចេះ ០១ អណ្តូង ។

3.4. **ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷** (គ្មានសកម្មភាព)

3.5. **<u>ការិយាល័យអភិវឌ្ឍន៍សហគមន៍</u>**÷

- ចុះបណ្តុះបណ្តាល គ.អ.ភ នៅស្រុកឆ្លូង ស្តីពីការដោះស្រាយទំនាស់តាមសហគមន៍ បានចំនួន ០៥ វត្ត ស្មើនឹង ២០ ភូមិ ស្មើនឹង ០៤ ឃុំ និងមាន គ.អ.ភ ចូលរួមចំនួន ១៨៧ នាក់ ក្នុងនោះស្ត្រីមាន ១២០ នាក់ (សហការជាមួយអង្គការឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ) ។

3.6. **<u>ការិយាល័យជនជាតិដើមភាគតិច</u>**÷ (គ្មានសកម្មភាព)

3.7. **<u>ការិយាល័យថែទាំសុខភាពជនបទ</u>**÷

- បំផុសអោយប្រជាពលរដ្ឋចូលរួមស្ម័គ្រចិត្តសាងសង់បង្គន់ខ្លួនឯង បានចំនួន ៥៥១ បង្គន់ នៅស្រុកព្រែកប្រសព្វ ៣៦៦ បង្គន់ ស្រុកឆ្លូង ៥៩ បង្គន់ ស្រុកចិត្របុរី ១២៥ បង្គន់ និងស្រុកសំបូរ ១ បង្គន់ ។

3.8. **<u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ</u>**÷ មានចំនួន ៤លើក ។

**ប្រធានមន្ទីរ**